**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦៦ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលមាត្រា ២ នៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**មាត្រា មួយ:** ត្រូវបានកែសំរួលមាត្រា ២ នៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងកាប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ :

**មាត្រា ២ ថ្មី:** សមាសភាពក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានដូចតទៅ :

| | |
|---|---|
| ១- ឯកឧត្តមជាន់ខ្ពស់មួយរូប | ប្រធាន |
| ២- ឯកឧត្តមមួយ ឬច្រើនរូប | អនុប្រធាន |
| ៣- អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |

| | | |
|---|---|---|
| ៤- | រដ្ឋមន្ត្រីទទួលទីស្តីការគណៈរដ្ឋមន្ត្រី ឬ តំណាង | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬ តំណាង | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬ តំណាង | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ តំណាង | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬ តំណាង | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬ តំណាង | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ តំណាង | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងផែនការ ឬ តំណាង | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ តំណាង | សមាជិក |
| ១៤- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ តំណាង | សមាជិក |
| ១៥- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬ តំណាង | សមាជិក |
| ១៦- | អគ្គទេសាភិបាលធនាគារជាតិ ឬ តំណាង | សមាជិក |
| ១៧- | ប្រធានធនាគារអភិវឌ្ឍន៍ជនបទ ឬ តំណាង | សមាជិក |
| ១៨- | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ តំណាង | សមាជិក |
| ១៩- | ប្រធានមូលនិធិកាត់បន្ថយភាពក្រីក្រ ឬ តំណាង | សមាជិក |
| ២០- | អគ្គលេខាធិការ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម | សមាជិក |
| ២១- | អគ្គនាយកមូលនិធិសង្គម នៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |
| ២២- | មេបញ្ជាការ នៃបញ្ជាការដ្ឋានវិស្វកម្ម នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |

**មាត្រា ពីរ:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៨

*កន្លែងទទួល :*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ពីរ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**